ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨

****

I- សេចក្ដីផ្ដើម

១. ស្ថិតក្នុងបរិការណ៍សុខសន្តិភាព, ឯកភាពជាតិ និងស្ថិរភាពនយោបាយ, ប្រទេសកម្ពុជាបាន និងកំពុងក្រេបជញ្ជក់នូវផ្លែផ្កាកំណើន និងកិច្ចអភិវឌ្ឍន៍លើគ្រប់វិស័យ ព្រមទាំងបានប្រែក្លាយខ្លួនទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប។ សមិទ្ធផលដែលសម្រេចបានកន្លងមកនេះ បាននាំមកនូវមោទនភាព, ភាពជឿជាក់ និងការទទួលស្គាល់ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ និងក្ដីសង្ឃឹមយ៉ាងមុតមាំសម្រាប់ប្រជាជន និងប្រទេសជាតិក្នុងការកសាងកម្ពុជាឆ្ពោះទៅរកការសម្រេចបង្គោលចរមួយទៀត គឺក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។ ឈរលើមូលដ្ឋាននេះ, រាជរដ្ឋាភិបាលកម្ពុជាមានការប្ដេជ្ញាចិត្តខ្ពស់ និងមានភាព-សកម្មជាងពេលណាៗទាំងអស់ ក្នុងការបន្តការអនុវត្តការកែទម្រង់ឱ្យកាន់តែស៊ីជម្រៅ, មុតស្រួច និងគ្រប់ជ្រុងជ្រោយ ជាពិសេសដើម្បីឆ្លើយតបទៅនឹងដំណើរការផ្លាស់ប្ដូរជារចនាសម្ព័ន្ធនូវស្ថានភាពសង្គម-សេដ្ឋកិច្ច ទាំងក្នុង និងក្រៅប្រទេស។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលចាំបាច់ត្រូវមានការគិតគូរថ្មី និងធ្វើសកម្មភាពថ្មីបន្ថែមទៀត ក្នុងការបន្តគ្រប់-គ្រងស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ដើម្បីរក្សាបាននូវកំណើនខ្ពស់ប្រកបដោយចីរភាព, បរិយាប័ន្ន, សមធម៌ និងភាពធន់ទៅនឹងវិបត្តិដើម្បីរួមចំណែកបន្តកសាងកម្ពុជាឱ្យមានភាពរឹងមាំ, សុខដុមរមនានិងវិបុលភាព ក្នុងសង្គមជាតិទាំងមូល។

២. ជាការពិត, ក្នុងឆ្នាំ២០១៦, ប្រទេសកម្ពុជាត្រូវបានធនាគារពិភពលោកចាត់ចូលក្នុងចំណោមប្រទេស **ឯក-ឧត្ដមករកំណើន** ទាំងប្រាំបីនៅក្នុងពិភពលោក ដែលមានកំណើនសេដ្ឋកិច្ចរឹងមាំក្នុងអត្រា ៧,៧% ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមក។ ជាមួយគ្នានេះដែរ, ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក៏បានកោតសរសើរយ៉ាងខ្លាំងចំពោះការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា ដែលបានផ្លាស់ប្ដូរពីប្រទេសក្រីក្រ និងមានជម្លោះផ្ទៃក្នុងរ៉ាំរ៉ៃ ទៅជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចលឿនបំផុតនៅតំបន់អាស៊ី ហើយបានប្រសិទ្ធនាមប្រទេសកម្ពុជា ជា "**ខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី**" ទៀតផង។ បន្ថែមលើនេះទៀត, អត្រាអតិផរណាបានស្ថិតនៅក្នុងកម្រិតទាប និងអាចគ្រប់គ្រងបាន, អត្រាប្ដូរប្រាក់មានស្ថិរភាព, វិស័យហិរញ្ញវត្ថុ និងធនាគារកាន់តែមានការរីកលូតលាស់, ខណៈដែលកម្ពុជាបន្តរក្សាបាននូវភាពទាក់ទាញសម្រាប់ការវិនិយោគ។ ជាមួយនឹងសមិទ្ធផលខាងលើ, ផ្លែផ្កានៃកំណើនត្រូវបានបែងចែកកាន់តែមានសមធម៌ និងទូលំទូលាយជាងមុន។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ័ : ៨៥៥-២៣-៤៣០ ២២៥ ទូរសារ : ៨៥៥-២៣-៤៣០ ៧៩៩
Phone : 855-23-430 225 / Fax : 855-23-430 799

៣. ដោយឡែកសម្រាប់បរិការណ៍សកល, ឆ្នាំ ២០១៦ កន្លងទៅនេះបានបង្ហាញឱ្យឃើញកាន់តែច្បាស់នូវការប្រែប្រួលយ៉ាងខ្លាំងនូវនិម្មាបនកម្មសេដ្ឋកិច្ច, ពាណិជ្ជកម្ម និងភូមិសាស្ត្រនយោបាយទាំងក្នុងកម្រិតតំបន់ និងសកល។ ពិភពលោកកំពុងប្រឈមនូវនិន្នាការថ្មីៗមួយចំនួនដូចជា ការលេចឡើងនូវចរន្តប្រឆាំងសកលភាវូបនីយកម្ម, ការការពារនិយមដែលរាំងខ្ទប់ការធ្វើពាណិជ្ជកម្មសេរី, ការកើនឡើងនូវការប្រើប្រាស់គោលនយោបាយប្រជាភិថុតិនិយមនៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចលូតលាស់ និងការប្រឆាំងនឹងការធ្វើអន្តោប្រវេសន៍ ដែលនិន្នាការបែបជាតិនិយមទាំងនេះបានជះឥទ្ធិពលអវិជ្ជមាន (Negative Spillovers) ដល់ប្រទេសដទៃទៀត និងកំពុងបង្កើតភាពស្មុគស្មាញ និងភាពមិនប្រាកដប្រជាកាន់តែខ្លាំងដល់ស្ថានភាពភូមិសាស្ត្រនយោបាយ និងបញ្ហាសន្តិសុខពិភពលោក ក៏ដូចជាបង្កើនហានិភ័យកាន់តែខ្ពស់ដល់សេដ្ឋកិច្ច, ពាណិជ្ជកម្ម និងហិរញ្ញវត្ថុសកលលោក, តំបន់ និងប្រទេស។

៤. ក្នុងបរិបទសកលថ្មីនេះ, សេដ្ឋកិច្ចកម្ពុជាក៏កំពុងប្រឈមនឹងហានិភ័យខាងក្រៅ ដូចជា កំណើនទន់ខ្សោយនៃប្រទេសមានសេដ្ឋកិច្ចអភិវឌ្ឍន៍, ភាពមិនច្បាស់លាស់នៃវិត្តារកម្មគោលនយោបាយសារពើពន្ធ និងការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិក, ការចាកចេញរបស់ប្រទេសអង់គ្លេស និងអនាគតរបស់សហភាពអឺរ៉ុប, កំណើនថមថយរបស់សេដ្ឋកិច្ចចិន, ភាពមិនច្បាស់លាស់នៃគោលនយោបាយសេដ្ឋកិច្ច និងពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិកក្រោមការដឹកនាំរបស់ប្រធានាធិបតីថ្មី។ល។ លើសពីនេះ, ការរំពឹងទុកនូវការងើបឡើងវិញនូវតម្លៃប្រេង និងទំនិញលើទីផ្សារអន្តរជាតិក៏ជាហានិភ័យសម្រាប់សេដ្ឋកិច្ចកម្ពុជាផងដែរ។

៥. ចំពោះហានិភ័យក្នុងប្រទេស, ការវិភាគបានបង្ហាញថា សេដ្ឋកិច្ចកម្ពុជាបានឈានដល់ចំណុចមួយ ដែលរាជរដ្ឋាភិបាលចាំបាច់ត្រូវជំរុញអនុវត្តឱ្យបានខ្លាំងក្លានូវវិធានការ និងយុទ្ធសាស្ត្រនានា ដែលបានដាក់ចេញកន្លងមកព្រមទាំងចាត់វិធានការមុតស្រួច និងចាំបាច់បន្ថែមនៅក្នុងវិស័យមួយចំនួន ដើម្បីទ្រទ្រង់កំណើនក្នុងរង្វង់ ៧% ប្រកបដោយចីរភាព និងរឹងមាំក្នុងរយៈពេលមធ្យម និងវែង។ ជាងពីរទសវត្សរ៍មកនេះ សេដ្ឋកិច្ចកម្ពុជាអាចសម្រេចបានកំណើនខ្ពស់ប្រកបដោយនិរន្តភាពដោយពឹងផ្អែកលើវិស័យកសិកម្ម, វិស័យកាត់ដេរ, វិស័យសំណង់ និងវិស័យទេសចរណ៍។ ក៏ប៉ុន្តែប៉ុន្មានឆ្នាំចុងក្រោយនេះ, វិស័យទាំងនេះបាននិងកំពុងបង្ហាញនូវសញ្ញាថមថយមួយចំនួនដែលមិនអាចទ្រទ្រង់កំណើនសេដ្ឋកិច្ចដូចឆ្នាំមុនៗទៀតបាន។ ជាក់ស្តែង, កំណើននៃតម្លៃបន្ថែមរបស់វិស័យទេសចរណ៍មានកម្រិតទាប ហើយនៅទ្រឹងនៅក្នុងរយៈពេលបួនឆ្នាំចុងក្រោយនេះ, វិស័យកាត់ដេរ និងវិស័យសំណង់អាចនឹងបន្តមានកំណើនថមថយនៅឆ្នាំខាងមុខ ខណៈដែលអនុបាតនៃការនាំចេញធៀបនឹង ផសស ក្នុងស្រុកក៏មានភាពទ្រឹង (៤៥% នៃ ផសស)។ ទន្ទឹមនឹងនេះ, កម្ពុជាក៏កំពុងបន្តប្រឈមនឹងបញ្ហាក្នុងសេដ្ឋកិច្ចមួយចំនួនទៀត រួមមានៈ ក) តម្លៃអគ្គិសនីនៅខ្ពស់ដែលបន្តដាក់បន្ទុកដល់វិនិយោគិន បើទោះជាតម្លៃនេះបានធ្លាក់ចុះបន្តិចក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ; ខ) ការកើនឡើងជាលំដាប់នៃបៀវត្សរ៍អប្បបរមា ដែលធ្វើឱ្យសឹករិចរិលនូវភាពប្រកួតប្រជែងរបស់កម្ពុជាធៀបនឹងប្រទេសជិតខាង; គ) ការបន្តបង់កម្រៃសេវាក្រៅផ្លូវការដែលនៅតែបន្តជាបញ្ហានៅឡើយក្នុងការធ្វើធុរៈកិច្ចនៅកម្ពុជា; ឃ) នីតិវិធីស្មុគស្មាញមួយចំនួនដែលមិនចាំបាច់ នៅតែបន្តជាឧបសគ្គ ដែលធ្វើឱ្យការទាក់ទាញការវិនិយោគបន្ថែម

មកកម្ពុជា មិនអាចឈានទៅដល់ចំណុចសក្តានុពលខ្ពស់បំផុត; និង ង) ថ្លៃម្ហូបអាហារនៅកម្ពុជាមាននិន្នាការកើនឡើងលឿនជាងកំណើនថ្លៃនៃមុខទំនិញដទៃទៀត ទោះបីថ្លៃកសិផលជាសកលមាននិន្នាការថយក៏ដោយ។

៦. ស្ថិតក្នុងបរិការណ៍នេះ, ដើម្បីបន្តរក្សាកំណើនប្រកបដោយចីរភាព និងធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនៅឆ្នាំបន្តបន្ទាប់ទៀត, កម្ពុជាចាំបាច់ត្រូវតាមដាននូវការវិវត្តនៃស្ថានភាពខាងលើឱ្យបានហ្មត់ចត់ និងជាប់ជាប្រចាំ ហើយឈានទៅដាក់ចេញនូវវិធានការគន្លឹះ ដើម្បីបញ្ចៀសហានិភ័យជាយថាហេតុ។ ទន្ទឹមនេះដែរ, រាជរដ្ឋាភិបាលនឹងបន្តការអនុវត្តវិធានការដែលមានស្រាប់ និងចាត់វិធានការមុតស្រួចបន្ថែម ក្នុងការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច សំដៅជំរុញការធ្វើពិពិធកម្មទៅរកវិស័យថ្មីៗដែលមានតម្លៃបន្ថែមខ្ពស់ និងការកែលម្អបរិយាកាសវិនិយោគឱ្យបានកាន់តែល្អប្រសើរ ដើម្បីធានាចីរភាពនៃកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ ជាពិសេសតាមរយៈការដាក់ចេញ និងអនុវត្តនូវវិធានការគោលនយោបាយ ដែលមានលក្ខណៈឆ្លើយតប ទាំងនៅក្នុងផ្នែកម៉ាក្រូសេដ្ឋកិច្ច និងផ្នែកហិរញ្ញវត្ថុសាធារណៈ។ ម្យ៉ាងទៀត, សមាហរណកម្មអាស៊ាន និងសេដ្ឋកិច្ចក្នុងតំបន់កំពុងតែរីកចម្រើន និងនាំមុខគេ ស្របពេលដែលខ្សែចង្វាក់តម្លៃតំបន់បាន និងកំពុងមានការផ្លាស់ប្តូរ ដែលនេះគឺជាកាលានុវត្តភាពមួយយ៉ាងសំខាន់សម្រាប់កម្ពុជាត្រូវចាប់យក និងប្រើប្រាស់ឱ្យអស់លទ្ធភាពក្នុងរយៈពេល ៥ ឆ្នាំខាងមុខ ដើម្បីធ្វើសមាហរណកម្មឧស្សាហកម្មឱ្យបានជោគជ័យ ចូលទៅក្នុងបណ្តាញផលិតកម្មក្នុងតំបន់ និងសកល ក្នុងគោលដៅធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចរបស់ខ្លួន។

I- ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

៧. សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ ២០១៦ កន្លងទៅ នៅបន្តមានកំណើនរឹងមាំ ដោយសម្រេចបានកំណើន ៧% ដោយសារតែការងើបឡើងវិញនៃកំណើនក្នុងវិស័យកសិកម្ម បន្ទាប់ពីស្ទើរតែគ្មានកំណើនសោះក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ ខណៈដែលកំណើនវិស័យឧស្សាហកម្ម និងសេវាកម្មមានភាពថមថយបន្តិច។ ការថមថយនៃកំណើនក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មនេះ បានបង្ហាញពីភាពចាំបាច់ និងជាបន្ទាន់នៃការធ្វើការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច និងការធ្វើពិពិធកម្ម ក្នុងគោលដៅស្វែងរកជន្ទល់ថ្មីៗ ដែលមានតម្លៃបន្ថែមខ្ពស់ដល់សេដ្ឋកិច្ច ដើម្បីបន្តធានាចីរភាពនៃកំណើនក្នុងរយៈពេលមធ្យម និងវែង។ ក្នុងឆ្នាំ ២០១៧ និងឆ្នាំ ២០១៨ នេះ, សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងនៅបន្តកំណើនរឹងមាំក្នុងរង្វង់ប្រមាណ ៧% ដូចដែលបានគ្រោងទុក ដែលទ្រទ្រង់ដោយកំណើនល្អនៃវិស័យកសិកម្ម និងឧស្សាហកម្ម ជាពិសេសវិស័យកាត់ដេរ, ផលិតកម្មមិនមែនកាត់ដេរ និងផលិតកម្មដែលបម្រើឱ្យការប្រើប្រាស់ក្នុងស្រុក។ ផ្អែកលើនិន្នាការខាងលើ, សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០១៧ និង ២០១៨ ត្រូវបានព្យាករដូចខាងក្រោម÷

(១)- វិស័យកសិកម្មត្រូវបានព្យាករថានៅតែរក្សាបានកំណើនប្រមាណ ២,០% ក្នុងឆ្នាំ ២០១៧ និងឆ្នាំ ២០១៨។ វិស័យដំណាំរំពឹងថានឹងមានកំណើនប្រមាណ ២,១% និង ១,៩% នៅឆ្នាំ ២០១៧ និង ២០១៨ ដែលកំណើននេះ បានមកដោយការកើនឡើងផលិតកម្មកៅស៊ូ និងដំណាំបន្ទាប់បន្សំដូចជា ដំឡូងមី និងពោត ។ ដំណាំស្រូវត្រូវបានរំពឹងថានឹងមានកំណើនយឺតដោយសារតែផ្ទៃដីដាំដុះពុំអាចពង្រីកបន្តទៀត ស្របពេលដែលផលិតភាពកើនឡើងយឺត និងតម្លៃមានភាពមិននឹងនរ។ ទន្ទឹមនឹងនេះ, ការវិនិយោគលើវិស័យកសិឧស្សាហកម្មដូចជាការផលិតចំណីសត្វ, ប្រេង

អេតាណុល និងស្ករសជាដើម នឹងបន្តជំរុញផលិតកម្មនៃដំណាំទាំងនោះឱ្យមានការកើនឡើង។ វិស័យកសិកម្មផ្សេង-ទៀត ដែលរួមមាន ជលផល និងការចិញ្ចឹមសត្វ ក៏ត្រូវបានព្យាករថានឹងបន្តកំណើនល្អ ដោយសារតែមានការរំពឹងទុកអំពីការបន្តកើនឡើងនៃការវិនិយោគលើវិស័យវារីវប្បកម្ម និងការបន្តពង្រីកអាជីវកម្មចិញ្ចឹមមាន់ និងជ្រូកដោយក្រុម-ហ៊ុនឯកជនក្នុងទម្រង់ជាកសិកម្មបែបកិច្ចសន្យា (Contract Farming)។

(២)- វិស័យឧស្សាហកម្មក៏អាចបន្តរក្សាកំណើនខ្ពស់ក្នុងអត្រា ១០,៧% ក្នុងឆ្នាំ ២០១៧ និង ១០,១% ក្នុងឆ្នាំ ២០១៨ ដែលគាំទ្រដោយវិស័យកាត់ដេរ និងសំណង់ ជាពិសេសវិស័យផលិតកម្មមិនមែនកាត់ដេរ។ ក្នុងនោះវិស័យកាត់ដេរត្រូវបានព្យាករថានឹងមានកំណើនងើបឡើងវិញបន្តិចក្នុងរង្វង់ ៨,៥% ក្នុងឆ្នាំ ២០១៧។ ការបន្តកំណើននៃវិស័យនេះ បណ្តាលមកពីការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ចរបស់ប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗ រួមមានៈ សហរដ្ឋអា-មេរិក និងប្រទេសភាគច្រើនក្នុងតំបន់អឺរ៉ុប, ការដកខ្លួនរបស់សហរដ្ឋអាមេរិកពីកិច្ចព្រមព្រៀងពាណិជ្ជកម្មភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (TPP) ដែលធ្វើឱ្យរោងចក្រកាត់ដេរមួយចំនួន ដែលបានផ្លាស់ទីតាំងទៅប្រទេសវៀតណាមអាចពិចារណាឡើងវិញ បើទោះបីជាមានការប្រឈមនឹងហានិភ័យមួយចំនួននៅកម្ពុជាដូចជា ការកើនឡើងប្រាក់ឈ្នួលអប្ប-បរមា និងការខិតជិតមកដល់នៃការបោះឆ្នោត ព្រមជាមួយនឹងហានិភ័យខាងក្រៅផ្សេងទៀត រួមមាន ការចាកចេញរបស់ប្រទេសអង់គ្លេសពីសហគមន៍អឺរ៉ុបក៏ដោយ។ ក្នុងឆ្នាំ ២០១៨, វិស័យកាត់ដេរអាចនឹងមានកំណើនថមថយបន្តិចមកត្រឹម ៨,0% បើទោះបីជាស្ថានភាពសេដ្ឋកិច្ចនៃប្រទេសដែលជាដៃគូពាណិជ្ជកម្មត្រូវបានព្យាករនៅតែមានភាពល្អប្រសើរ ។ ការព្យាករកំណើនយឺតនៃវិស័យកាត់ដេរក្នុងឆ្នាំ ២០១៨ ធៀបនឹងឆ្នាំ ២០១៧ គឺបណ្តាលមកពីស្ថានភាពមិនច្បាស់លាស់នៃការវិនិយោគក្នុងឆ្នាំបោះឆ្នោតសកល និងការប្រកួតប្រជែងកាន់តែខ្លាំងពីប្រទេសមីយ៉ាន់ម៉ា និងវៀត-ណាម ជាពិសេស នៅពេលដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) រវាងវៀតណាម និងសហភាពអឺរ៉ុបចូលជាធរមាន។

បន្ទាប់ពីមានកំណើនជាមធ្យមប្រមាណ ១៩% ក្នុងឆ្នាំ ២០១៤-២០១៦ វិស័យសំណង់ត្រូវបានព្យាករថាអាចនឹងមានកំណើនថយមកត្រឹម១៤,១%សម្រាប់ឆ្នាំ ២០១៧ និង ១២,៤% សម្រាប់ឆ្នាំ ២០១៨ ដោយសារឥរិយាបថ"**រង់-ចាំមើល**" (Wait-and-See) របស់វិនិយោគិនក្នុងការវិនិយោគបន្ថែម និងកំណើននៃការផ្គត់ផ្គង់ដ៏ច្រើនលើសលប់ ធៀបនឹងតម្រូវការជាក់ស្តែងចំពោះប្រភេទសំណង់លំនៅដ្ឋានដែលមានតម្លៃខ្ពស់។ ជានិន្នាការ, ការសាងសង់ខុនដូរ និងបុរីដែលមានតម្លៃខ្ពស់មានសភាពនៅទ្រឹង ប៉ុន្តែបានប៉ះប៉ូវដោយគម្រោងលំនៅដ្ឋានដែលមានតំលៃសមរម្យ, ការបន្តកើនឡើងនៃការសាងសង់សំណង់ការិយាល័យ និងសំណង់ផ្សេងៗទៀត ដូចជាការបញ្ចប់ការសាងសង់មជ្ឈមណ្ឌលផ្សារទំនើប ស្របជាមួយនឹងនិន្នាការនៃការលូតលាស់យ៉ាងឆាប់រហ័សផ្នែកនគរូបនីយកម្មនៅរាជធានីភ្នំពេញ និងតាមខេត្តធំៗមួយចំនួនដូចជា ខេត្តព្រះសីហនុជាដើម ដែលអាចនឹងជួយបន្តជំរុញកំណើននៃវិស័យនេះ។ ចំណែកគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធធំៗ ដែលរួមមានគម្រោងជួសជុល និងពង្រីកផ្លូវជាតិលេខ ៥ ពី ២ គន្លង ទៅ ៤ គន្លងដែលមានទឹកប្រាក់ប្រមាណ ១៦០ លានដុល្លារអាមេរិក និងគម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ ដែល

មានទឹកប្រាក់ប្រមាណ ១,៦ ប៊ីលានដុល្លារអាមេរិក នឹងត្រូវចាប់ផ្តើមសាងសង់នៅក្នុងឆ្នាំ ២០១៧។ ជារួម, កំណើនថមថយនៃវិស័យសំណង់នៃវិស័យឯកជនជាសញ្ញាល្អមួយ ព្រោះថាវិស័យនេះកំពុងឈានចូលដំណាក់នៃការផ្លាស់ប្តូរទីផ្សារ និងពិពិធកម្មទីផ្សារអចលនវត្ថុ ខណៈដែលការកើនឡើងនៃវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត នឹងជួយប៉ះប៉ូវមួយផ្នែកនៃការធ្លាក់ចុះការវិនិយោគក្នុងវិស័យឯកជន ជាពិសេសចូលរួមលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិឱ្យកាន់តែប្រសើរឡើង។

ចំណែកវិស័យឧស្សាហកម្មផ្សេងៗ ដែលមានដូចជា វិស័យម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់, វិស័យគ្រឿងបង្គុំអេឡិចត្រូនិច និងគ្រឿងបន្លាស់រថយន្ត, វិស័យថាមពល និងវិស័យផលិតកៅស៊ូក្រែប មានសន្ទុះខ្លាំងក្នុងការទ្រទ្រង់វិស័យឧស្សាហកម្ម ក៏ដូចជាផលិតផលក្នុងស្រុកសរុបផងដែរ។ វិស័យម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ មានការកើនឡើងជាបន្តបន្ទាប់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈកំណើនតម្រូវការប្រើប្រាស់របស់ប្រជាជនក្នុងស្រុក និងការកើនឡើងនៃផលិតកម្មក្នុងស្រុកជំនួសឱ្យការនាំចូល។ រោងចក្រផលិតម្ហូបអាហារ និងភេសជ្ជៈចំនួន ១៤ ត្រូវបានបង្កើតថ្មីក្នុងឆ្នាំ ២០១៦ ដែលរួមមាន រោងចក្រផលិតទឹកផ្លែឈើ, ទឹកក្រូច, ភេសជ្ជៈប៉ូវកំលាំង, ស្រាបៀរ និងសហគ្រាសផលិតនំកញ្ចប់, អាហារកំប៉ុង, ទឹកស៊ីអ៊ីវ, ទឹកត្រី, អំបិល...។ល។ ជាការកត់សម្គាល់, រោងចក្រកូកាកូឡាថ្មីមួយទៀត ត្រូវបានចាប់ផ្តើមដំណើរការនាឆ្នាំ ២០១៦ កន្លងទៅ ស្របពេលដែលមានការកើនឡើងគួរឱ្យកត់សម្គាល់នូវការដាក់លក់ផលិតផលអាហារ និងភេសជ្ជៈផលិតក្នុងស្រុកតាមផ្សារទំនើបផ្សេងៗ ដែលជាសញ្ញាដ៏ល្អនៃការកើនឡើងការផលិតអាហារ និងភេសជ្ជៈក្នុងស្រុក។ គម្រោងបង្កើនការផលិតអាហារ និងភេសជ្ជៈក្នុងស្រុកបន្ថែមទៀតជំនួសឱ្យការនាំចូលក្នុងឆ្នាំ ២០១៧ និង២០១៨ នឹងធ្វើឱ្យវិស័យនេះរួមចំណែកកាន់តែធំជាងមុននៅក្នុងសេដ្ឋកិច្ចជាតិ។ កំណើននៃវិស័យថាមពល, ដោយសារកំណើននៃការផ្គត់ផ្គង់អគ្គិសនីពីទំនប់វារីអគ្គិសនីក្នុងស្រុកមួយចំនួន, បានរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយបរិមាណអគ្គិសនីដែលនាំចូលពីប្រទេសជិតខាង និងធ្វើឱ្យតម្លៃអគ្គិសនីនៅកម្ពុជាកាន់តែមានកម្រិតសមរម្យជាងមុន។ វិស័យគ្រឿងបង្គុំអេឡិចត្រូនិច និងគ្រឿងបន្លាស់រថយន្តក៏មានសន្ទុះខ្លាំងផងដែរ ដោយវិនិយោគិនជប៉ុនបានបន្តបង្កើតរោងចក្រថ្មីបន្ថែមទៀតក្នុងតំបន់សេដ្ឋកិច្ចពិសេសនៅទីក្រុងប៉ោយប៉ែត សម្រាប់បម្រើការនាំចេញទៅក្រៅប្រទេស។ ជាក់ស្តែង, កន្លងមកកម្ពុជាបាននិងកំពុងទទួលបានអត្ថប្រយោជន៍តាមរយៈការផ្លាស់ប្តូរទីតាំងរោងចក្រពីប្រទេសអភិវឌ្ឍន៍ទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាការអនុវត្តយុទ្ធសាស្ត្រចិនបូក ១ និងថៃបូក ១ ដើម្បីពង្រឹងភាពប្រកួតប្រជែង និងធ្វើពិពិធកម្មមូលដ្ឋានផលិតកម្ម។ ការកើនឡើងជាលំដាប់នៃតម្លៃកៅស៊ូលើទីផ្សារអន្តរជាតិ បានរួមចំណែកជំរុញការផលិតកៅស៊ូក្រែបនៅកម្ពុជាឱ្យកាន់តែមានកំណើនប្រសើរថែមទៀតក្នុងឆ្នាំ ២០១៧ និង ២០១៨។

(៣)- វិស័យសេវាកម្មត្រូវបានព្យាករថាបន្តសម្រេចបានកំណើនខ្ពស់ក្នុងរង្វង់ ៦,៥% និង ៦,៧% ក្នុងឆ្នាំ ២០១៧ និង ២០១៨។ វិស័យទេសចរណ៍ត្រូវបានព្យាករថានឹងងើបឡើងវិញបន្តិចក្នុងអត្រា ២,៣% ក្នុងឆ្នាំ ២០១៧ ដោយសារការដាក់ចេញនូវគោលនយោបាយមួយចំនួនរបស់រាជរដ្ឋាភិបាល ដើម្បីជំរុញកំណើនទេសចរអន្តរជាតិ

ដូចជា គោលនយោបាយទាក់ទាញភ្ញៀវទេសចរជនជាតិចិន និងការផ្តល់ទិដ្ឋាការចេញ-ចូលច្រើនដងក្នុងរយៈពេលបីឆ្នាំសម្រាប់ភ្ញៀវទេសចរជនជាតិចិន, កូរ៉េ និងជប៉ុន ដែលបានដាក់ចេញក្នុងខែ កញ្ញា ឆ្នាំ ២០១៦។ ទោះជាយ៉ាងណាក៏ដោយ, វិស័យទេសចរណ៍ទំនងជានៅបន្តមានកំណើនទាប ប្រសិនបើមិនមានគោលនយោបាយជាក់លាក់ណាមួយក្នុងការបន្តធ្វើពិពិធកម្មគោលដៅ និងផលិតផលទេសចរណ៍ ឬការបើកទីផ្សារទេសចរណ៍ថ្មីបន្ថែមសម្រាប់ភ្ញៀវទេសចរចាស់ ដូចជាភ្ញៀវទេសចរវៀតណាម, ថៃ, កូរ៉េ និងជប៉ុន ដែលកំពុងបន្តនិន្នាការថយចុះ។ សម្រាប់ឆ្នាំ ២០១៨, វិស័យទេសចរណ៍អាចមានកំណើនថេរក្នុងអត្រា ២,៣% ដោយសារតែការរំពឹងទុកនៃកំណើនយឺតនៃប្រទេសដែលជាទីផ្សារទេសចរណ៍របស់កម្ពុជា និងភាពមិនប្រាកដប្រជានៃការវិនិយោគក្នុងឆ្នាំ ២០១៨ ខាងមុខ។ ជារួម, វិស័យទេសចរណ៍នឹងនៅតែបន្តដើរតួនាទីជាជន្ទល់ទ្រទ្រង់កំណើនដដែល ប៉ុន្តែចាំបាច់ត្រូវបន្តធ្វើពិពិធកម្មឱ្យអស់សក្តានុពល ជាពិសេសការធ្វើពិពិធកម្មគោលដៅ និងផលិតផលទេសចរណ៍ ឬការបើកទីផ្សារទេសចរណ៍ថ្មី ដើម្បីបង្កើនតម្លៃបន្ថែមនៃវិស័យនេះក្នុងសេដ្ឋកិច្ចជាតិ។

ចំណែកវិស័យលក់ដុំ និងរាយ ត្រូវបានព្យាករថានឹងមានកំណើនរឹងមាំក្នុងរង្វង់អត្រា ៧,៨% និង ៨,៣% ក្នុងឆ្នាំ ២០១៧ និង ២០១៨ ដោយសារការរំពឹងទុកនៃការបន្តកើនឡើងនូវការប្រើប្រាស់ក្នុងស្រុក។ ជាក់ស្តែង, ក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ការប្រើប្រាស់ក្នុងស្រុកត្រូវបានសង្កេតឃើញថាមានសន្ទុះកំណើនកាន់តែខ្លាំងដោយសារកំណើននៃប្រជាជនដែលមានចំណូលមធ្យម (Middle Class), កំណើនយុវជន និងការផ្លាស់ប្តូររបៀបរស់នៅរបស់សង្គម (Lifestyle) ទាក់ទងនឹងចំណាយលើការប្រើប្រាស់ ដែលបានធ្វើឱ្យវិស័យនេះជួយជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាបន្ថែមទៀត។ ម្យ៉ាងវិញទៀត, ការអនុវត្តគោលនយោបាយវិភាគកម្មថវិការបស់រាជរដ្ឋាភិបាល តាមរយៈការតម្លើងបៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ, ការបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក៏ដូចជាការតម្លើងបៀវត្សអប្បបរមាក៏នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញ និងបង្កើនសមត្ថភាពចំណាយក្នុងស្រុក ជំនួសឱ្យការថមថយកំណើននៃវិស័យផ្សេងទៀតដូចជា វិស័យកាត់ដេរ, សំណង់ និងអចលនទ្រព្យ។ ចំណែកវិស័យអចលនទ្រព្យនៅឆ្នាំ ២០១៧ និង ២០១៨ ត្រូវបានព្យាករថានឹងមានអត្រាកំណើនទាបជាងឆ្នាំ ២០១៦ ស្របជាមួយកំណើនថមថយនៃវិស័យសំណង់ ដោយសារហេតុផលនៃភាពមិនច្បាស់លាស់នៃស្ថានភាពវិនិយោគនាឆ្នាំខាងមុខ និងកំណើននៃការផ្គត់ផ្គង់ដែលច្រើនលើសលប់ធៀបនឹងតម្រូវការ ប៉ុន្តែអាចមានកំណើនឡើងបន្តិចវិញនៅឆ្នាំបន្តបន្ទាប់ទៀត។ ដោយឡែក, វិស័យទូរគមនាគមន៍នឹងបន្តរីកចម្រើនកាន់តែខ្លាំង ដោយសារការវិនិយោគកាន់តែច្រើន ជាពិសេស លើហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យាថ្មីៗ, ការពង្រីកតំបន់គ្របដណ្តប់ និងសេវាកម្មនៅតាមតំបន់ប្រជុំជននានា។ កត្តានេះនឹងជំរុញឱ្យទីផ្សារវិស័យទូរគមនាគមន៍កាន់តែមានភាពរស់រវើកជាងមុន។ ទោះបីជាមានកំណើនថមថយបន្តិចនាឆ្នាំ ២០១៧ និង ២០១៨ វិស័យដឹកជញ្ជូនទំនងជាមានភាពប្រសើរឡើងក្នុងឆ្នាំ ២០១៩ និង ២០២០ ដោយហេតុថា ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនសំខាន់ៗមួយចំនួនអាចនឹងបញ្ចប់ ដែលក្នុងនោះរួមមានៈ ផ្នែកខ្លះនៃផ្លូវជាតិលេខ៥, ផ្នែកខ្លះនៃ

ផ្លូវរថភ្លើងភាគខាងជើង និងការពង្រីកកំពង់ផែក្រុងព្រះសីហនុជាដើម។ លើសពីនេះ, ការរៀបចំបង្កើតក្រុមប្រឹក្សាជាតិឡូជីស្ទីក រំពឹងថានឹងធ្វើឱ្យមានភាពប្រសើរឡើងនៃភាពប្រកួតប្រជែងខ្ពស់នៃវិស័យឡូជីស្ទីក និងដឹកជញ្ជូននៅកម្ពុជា។

កំណើនពិតតាមវិស័យ			
	២០១៦ ប៉ាន់ស្មាន	២០១៧ ព្យាករណ៍	២០១៨ ព្យាករណ៍
កំណើន ផសស	៧,០%	៧,០%	៧,០%
កសិកម្ម	១,៨%	២,០%	២,០%
ដំណាំ	២,៣%	២,១%	១,៩%
ការចិញ្ចឹមសត្វ	០,៥%	១,៤%	១,៥%
នេសាទ	១,៨%	២,៦%	២,៧%
ព្រៃឈើ	-១,៦%	-១,៧%	-១,៧%
ឧស្សាហកម្ម	១០,៥%	១០,៧%	១០,១%
កាត់ដេរ	៨,០%	៨,៥%	៨,០%
សំណង់	១៥,៩%	១៤,១%	១២,៤%
ឧស្សាហកម្មផ្សេងទៀត	១១,៦%	១២,៧%	១៣,០%
សេវាកម្ម	៦,៧%	៦,៥%	៦,៧%
ទេសចរណ៍	២,២%	២,៣%	២,៣%
លក់ដុំ និងលក់រាយ	៧,៤%	៧,៨%	៨,៣%
ដឹកជញ្ជូន និងគមនាគមន៍	៧,៦%	៧,៥%	៧,៤%
អចលនទ្រព្យ និងពាណិជ្ជកម្ម	៩,៥%	៨,៣%	៧,៩%

ប្រភព: ការប៉ាន់ស្មាន និងព្យាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ខែ កុម្ភៈ ឆ្នាំ ២០១៧

៨. អត្រាអតិផរណានៅកម្ពុជា រំពឹងថានឹងស្ថិតនៅក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន ទោះបីថ្លៃប្រេងលើទីផ្សារអន្តរជាតិអាចនឹងបន្តកើនឡើង ដោយអត្រាអតិផរណាមធ្យមប្រចាំឆ្នាំនឹងស្ថិតនៅត្រឹមប្រមាណ ៣,៨% និង ៣,៥% នៅឆ្នាំ២០១៧ និង ២០១៨ រៀងគ្នា បន្ទាប់ពីស្ថិតក្នុងកម្រិត ៣,០% នៅក្នុងឆ្នាំ ២០១៦។ ទោះជាយ៉ាងនេះក្ដី, ថ្លៃម្ហូបអាហារជាទូទៅនៅកម្ពុជាមាននិន្នាការកើនឡើងលឿនជាងមុខទំនិញដទៃទៀត ទោះបីថ្លៃកសិផលជាសកលមាននិន្នាការថមថយក៏ដោយ ដែលនេះជាកង្វល់សំខាន់មួយ និងទាមទារឱ្យរាជរដ្ឋាភិបាលត្រូវចាត់វិធានការបន្ទាន់ និងមុតស្រួច ដើម្បីកាត់បន្ថយសម្ពាធលើជីវភាពរស់នៅរបស់ប្រជាជននាពេលបច្ចុប្បន្ន និងអនាគត។ រាជរដ្ឋាភិបាលនឹងពិនិត្យមើលលើមូលហេតុនៃការកើនឡើងនៃថ្លៃម្ហូបអារហារ និងចាត់វិធានការមុតស្រួច ដើម្បីធានារក្សាថ្លៃម្ហូបអាហារឱ្យស្ថិតនៅក្នុងកម្រិតសមស្រប។ ចំណែកឯអត្រាប្តូរប្រាក់ដុល្លារអាមេរិកវិញ ត្រូវបានរំពឹងថានឹងមានស្ថិរភាពនៅឆ្នាំនេះ និងឆ្នាំបន្ទាប់ ដែលមានតម្លៃជាមធ្យមក្នុងរង្វង់ ៤ ០៣៧ រៀល ក្នុង ១ដុល្លារអាមេរិក។ កត្តាដែលរក្សាបាន

នូវអត្រាប្តូរប្រាក់ឱ្យមានស្ថិរភាព គឺមកពីកំណើនសេដ្ឋកិច្ចខ្ពស់របស់កម្ពុជា និងប្រសិទ្ធភាពក្នុងការបន្តអនុវត្តគោល-នយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយរូបិយវត្ថុបានល្អ។

៩. ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ) បានថយចុះមកត្រឹម ៧,៦% នៃ ផសស ក្នុងឆ្នាំ ២០១៦ ដែលបានឆ្លុះបញ្ចាំងតាមរយៈភាពប្រសើរឡើងនៃសមតុល្យពាណិជ្ជកម្ម ទោះបីសកម្មភាពពាណិជ្ជកម្មអន្តរជាតិជារួមមានការថមថយ។ ក្នុងឆ្នាំ ២០១៧ និង ២០១៨ ឱនភាពគណនីចរន្តត្រូវបានព្យាករថានឹងកើនឡើងបន្តិចមកវិញក្នុងអត្រាប្រមាណ ៧,៩% និង ៨,៥% នៃ ផសស រៀងគ្នា ដោយសារការរំពឹងទុកអំពីកំណើនយឺតបន្តិចនៃការនាំចេញ ខណៈឆ្នាំ ២០១៨ ជាឆ្នាំបោះឆ្នោតសកល។ ទោះបីជាការនាំចេញត្រូវបានព្យាករថាអាចនឹងមានកំណើនថមថយក៏ដោយក៏ការនាំចូលត្រូវបានរំពឹងថានឹងនៅតែកើនឡើង ស្របគ្នាទៅនឹងនិន្នាការកើនឡើងជាបន្តបន្ទាប់នៃផលិតកម្មក្នុងស្រុកដើម្បីបម្រើឱ្យការប្រើប្រាស់ក្នុងស្រុក ដែលរួមចំណែកកាន់តែធំក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ។ ជាមួយគ្នានោះដែរ ទុនបម្រុងអន្តរជាតិសរុបបានកើនឡើងដល់ ៦ ៧៣១ លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៦ (៥,៥ ខែនៃការនាំ-ចូល) ដោយសារការដាក់បញ្ចូលរូបិយវត្ថុចិន (ប្រាក់យ័ន) បន្ថែមលើទុនបម្រុងដែលមានស្រាប់ ហើយកំណើននេះត្រូវបានព្យាករថានឹងកើនឡើងដល់ ៧ ៥៣៨ លានដុល្លារអាមេរិក និង ៧ ៨៥៣ លានដុល្លារអាមេរិក ដែលធានាការនាំចូលប្រមាណ ៥,៧ ខែ និង ៥,៥ ខែ នៅឆ្នាំ ២០១៧ និង ២០១៨ រៀងគ្នា។

១០. ទោះជាយ៉ាងណាក៏ដោយ, ស្របទៅនឹងការព្យាករខាងលើ សេដ្ឋកិច្ចកម្ពុជាក៏អាចជួបប្រទះនូវហានិភ័យមួយចំនួនដូចជា÷ ការកើនឡើងនៃតម្លៃប្រាក់ដុល្លារអាមេរិកដែលនឹងនាំឱ្យប៉ះពាល់ដល់ភាពប្រកួតប្រជែងនៃការនាំ-ចេញ ក៏ដូចជាការទាក់ទាញទេសចរអន្តរជាតិ, កំណើនឥណទានទាបក្នុងវិស័យដែលមានផលិតភាពខ្ពស់ និងការ-គ្រប់គ្រងកំណើនឥណទានឱ្យស្ថិតក្នុងកម្រិតសមស្របមួយ, ការប្រែប្រួលអាកាសធាតុដែលនឹងផ្តល់ផលអាក្រក់ដល់កំណើនក្នុងវិស័យកសិកម្ម, ការចាកចេញរបស់ប្រទេសអង់គ្លេស និងភាពមិនច្បាស់លាស់នៃអនាគតសហភាពអឺរ៉ុបដែលអាចប៉ះពាល់ដល់ការនាំចេញរបស់កម្ពុជានិងកំណើនថមថយនៃសេដ្ឋកិច្ចចិនដែលអាចនឹងជះឥទ្ធិពលអវិជ្ជមានដល់ការវិនិយោគ និងវិស័យទេសចរណ៍របស់កម្ពុជា។ ក្នុងន័យនេះ, ដើម្បីបន្តជំរុញកំណើនឱ្យសម្រេចបានតាមការ-គ្រោងទុក, កម្ពុជាត្រូវដាក់ចេញនូវវិធានការគន្លឹះបី រួមមានៈ (ក) បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច; (ខ) ជំរុញកំណើនសេដ្ឋកិច្ចរឹងមាំប្រកបដោយបរិយាប័ន្ន និងធន់នឹងវិបត្តិ; និង (គ) ពន្លឿនការងារកំណែទម្រង់រចនាសម្ព័ន្ធស្ថាប័ន និងអភិវឌ្ឍធនធានមនុស្ស។

វិធានការគោលនយោបាយជាក់ស្តែងតាមផ្នែកគន្លឹះធំៗទាំងបីនេះ រួមមាន÷

(ក)- បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈ (១) ពង្រឹងយន្តការគ្រប់គ្រងហានិភ័យ និងវិបត្តិហិរញ្ញវត្ថុ; (២) ទ្រទ្រង់កំណើនឥណទានឱ្យស្ថិតក្នុងកម្រិតសមស្របមួយ និងបង្កើនគុណភាពនៃការផ្តល់ឥណទាន ដោយផ្តោតលើវិស័យផលិតកម្ម និងពាណិជ្ជកម្ម; (៣) បន្តខិតខំស្វែងរកប្រភពទុនថ្មីៗបន្ថែមទៀត សម្រាប់វិស័យឯកជន ជា-

ពិសេស ការអភិវឌ្ឍទីផ្សារសញ្ញាបណ្ណ (Bond Market) និងទីផ្សាររូបិយប័ណ្ណ (Money Market); (៤) បន្តផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រងវិស័យអចលនទ្រព្យ, តែខិតខំជំរុញការអភិវឌ្ឍលំនៅស្ថានដែលមានតម្លៃសមរម្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល; និង (៥) បង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋទូទៅ ជាពិសេសប្រជាពលរដ្ឋនៅតាមទីជនបទ ពាក់ព័ន្ធនឹងកម្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុ ព្រមទាំងបន្តពិនិត្យលទ្ធភាពបញ្ចុះថែមទៀតនូវអត្រាការប្រាក់ក្នុងវិស័យនេះ។

(ខ)- ជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ តាមរយៈ (១) ខិតខំទ្វេដងក្នុងការទាក់ទាញការវិនិយោគផ្ទាល់ពីក្រៅប្រទេស ដើម្បីបំពេញបន្ថែមការវិនិយោគនៅក្នុងស្រុក ដែលអាចនឹងថមថយដោយសារភាពមិនប្រាកដប្រជានាឆ្នាំ ២០១៨ ខាងមុខ; (២) ជំរុញការអនុវត្តគោលនយោបាយឧស្សាហកម្ម ដែលជាយុទ្ធសាស្ត្រកំណើនថ្មីរបស់ជាតិ ដោយជំរុញការអនុវត្តកន្លងមកដែលមិនទាន់ទទួលបានផ្លែផ្កា ឱ្យមានសន្ទុះខ្លាំងក្លាឡើង សំដៅជំរុញល្បឿននៃការធ្វើពិពិធកម្មមូលដ្ឋានឧស្សាហកម្មឱ្យកាន់តែឆាប់រហ័ស ដើម្បីបង្កើនភាពប្រកួតប្រជែង, បង្កើនតម្លៃបន្ថែមឱ្យកាន់តែខ្ពស់ក្នុងខ្សែចង្វាក់ផលិតកម្មនៃឧស្សាហកម្មកាត់ដេរ, កែច្នៃម្ហូបអាហារ, ការដំឡើងគ្រឿងម៉ាស៊ីន, គ្រឿងអេឡិចត្រូនិច និងឧស្សាហកម្មថ្មីទៀតដែលជំរុញសកម្មភាពសេដ្ឋកិច្ច; និង (៣) បង្កើនចំណាយលើវិស័យអាទិភាពសំខាន់ៗដូចជា អប់រំ, ការអភិវឌ្ឍជំនាញ, សុខាភិបាល, កសិកម្ម ព្រមទាំងការបង្កើនការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ និងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តសំខាន់ៗផ្សេងទៀត ដោយផ្អែកលើផែនការមេមួយច្បាស់លាស់ ជាពិសេសចំពោះវិស័យទូរគមនាគមន៍ និងដឹកជញ្ជូន និង វិស័យថាមពល ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពនៃចំណាយទាំងនេះ។

(គ)- ពន្លឿនការងារកំណែទម្រង់រចនាសម្ព័ន្ធស្ថាប័ន និងអភិវឌ្ឍធនធានមនុស្ស តាមរយៈ (១) ការគិតគូរឡើងវិញនូវគោលនយោបាយរយៈពេលវែង និងការដាក់ចេញនូវយុទ្ធសាស្ត្រថ្មីចំពោះវិស័យសំខាន់ៗមួយចំនួននៅក្នុងសេដ្ឋកិច្ច ដូចជាវិស័យកសិកម្ម និងវិស័យទេសចរណ៍ ដើម្បីជំរុញកំណើន, លើកកម្ពស់ផលិតភាព និងប្រសិទ្ធភាព ព្រមទាំងភាពប្រកួតប្រជែងរបស់កម្ពុជា; (២) ចាត់វិធានការមុតស្រួច សំដៅកាត់បន្ថយចំណាយលើការធ្វើធុរកិច្ច (Cost of Doing Business) តាមរយៈការរៀបចំជាបន្ទាន់នូវក្រុមការងារចង្អៀតមួយ ដើម្បីដោះស្រាយបញ្ហាចំណាយធុរៈកិច្ចទាំងនេះ ដោយពិនិត្យជាចាំបាច់ទៅលើបញ្ហាបទបញ្ញត្តិ, នីតិវិធីនៃការអនុវត្ត, គុណភាព និងការចំណាយលើសេវាសាធារណៈ ក្នុងគោលបំណងលើកកម្ពស់ឡូជីស្ទិកកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព សំដៅចូលរួមបង្កើនភាពប្រកួតប្រជែង និងបម្រើដល់វិស័យសេដ្ឋកិច្ចទាំងមូល; (៣) ពន្លឿនអភិវឌ្ឍធនធានមនុស្សមានជំនាញ ទាំងជំនាញកម្រិតទាប មធ្យម និងខ្ពស់ សំដៅជួយដល់ការអភិវឌ្ឍវិស័យឧស្សាហកម្មឱ្យកាន់តែខ្លាំងក្លាជាងមុន។

១១. ជារួម ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះ ត្រូវបានរៀបចំឡើងដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការរក្សាកំណើនខ្ពស់ប្រកបដោយចីរភាព, ស្ថិរភាពថ្លៃ, ការបង្កើតការងារ និងចីរភាពបំណុល។ ដើម្បីសម្រេចគោលបំណងខាងលើ, រាជរដ្ឋាភិបាលបានកំណត់គោលដៅកំណើន ផសស ឱ្យសម្រេចបានក្នុងអត្រា ៧,០ % ក្នុងឆ្នាំ

២០១៧ និង ២០១៨។ ជាមួយគ្នានេះដែរ, រាជរដ្ឋាភិបាល ក៏ដូចជាស្ថាប័នដែលមានសមត្ថកិច្ចផ្ទាល់នឹងត្រូវខិតខំចាត់វិធានការចាំបាច់នានា សំដៅរក្សាឱ្យបានស្ថិរភាពថ្លៃទំនិញនៅលើទីផ្សារ ក្នុងអត្រាអតិផរណាមធ្យមប្រចាំឆ្នាំឱ្យស្ថិតក្រោម ៥% ពោលគឺនៅក្នុងរង្វង់ ៣,៨% និង ៣,៥% នៅឆ្នាំ ២០១៧ និង ២០១៨។ ទន្ទឹមនឹងនេះ, រាជរដ្ឋាភិបាលនឹងបន្តធានារក្សាឱ្យបាននូវស្ថិរភាពអត្រាប្តូរប្រាក់ឱ្យស្ថិតក្នុងរង្វង់ ៤ ០៣៧ រៀល ក្នុង ១ ដុល្លារអាមេរិក ដោយខិតខំជំរុញលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលក្នុងសេដ្ឋកិច្ចជាតិ ទាំងសម្រាប់រយៈពេលចំពោះមុខ និងក្នុងរយៈពេលវែង។

II- ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

១២-ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំ ដោយឈរលើមូលដ្ឋាននៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដូចដែលបានគូសបញ្ជាក់ខាងលើ និង "**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣**", "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**" និង "**គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ២០១៥-២០២៥**" ដែលមានគោលបំណងសំខាន់ៗ ដូចតទៅ÷

- បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ;
- បន្តធានាអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន, ការងារ, សមធម៌ និងប្រសិទ្ធភាព ដើម្បីបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននិងបែងចែកផ្លែផ្កាកំណើនប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន;
- បន្តធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយបរិយាប័ន្ន និងចីរភាព ព្រមទាំងធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព;
- បន្តផ្តល់អាទិភាពដល់ការតម្លើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ឆ្ពោះទៅសម្រេចគោលដៅឱ្យបានលើស១ លានរៀល នៅឆ្នាំ ២០១៨ ដោយផ្សារភ្ជាប់ទៅនឹងការកែទម្រង់ប្រព័ន្ធបៀវត្ស និងការកែទម្រង់រដ្ឋបាលសាធារណៈ ជាពិសេសការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ;
- បន្តធានាអនុវត្តកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាលឱ្យមានលក្ខណៈស៊ីជម្រៅ និងទទួលបានលទ្ធផលជាផ្លែផ្កាជាក់ស្តែងជាបណ្តើរៗ រួមមានៈ ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ, ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងតុលាការ, និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព;
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងអត្រាឡើងថ្នាក់របស់សិស្ស;
- ជំរុញការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសទាំងកម្រិតទាប មធ្យម និងខ្ពស់ ដើម្បីផ្គត់ផ្គង់ពលកម្មជំនាញប្រកបដោយផលិតភាពឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការរបស់ធុរកិច្ច;

- បន្តលើកកម្ពស់សេវាសុខាភិបាលតាមរយៈការវិនិយោគបន្ថែម ទាំងលើអាគារមន្ទីរពេទ្យ, សម្ភារៈបរិក្ខារ និងសមត្ថភាពមន្ត្រីសុខាភិបាល;
- បន្តជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា សម្រាប់គាំទ្រដល់កំណើន និងការអភិវឌ្ឍ;
- បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម ពិសេសផ្តោតទៅលើការផលិតពូជល្អ, បន្លែ, ការចិញ្ចឹមសត្វ និងវារីវប្បកម្ម, ការនាំអង្ករចេញ ព្រមទាំងផលិតកម្មកែច្នៃម្ហូបអាហារ;
- ពង្រឹង និងពង្រីកលំហថវិកា រួមទាំងយន្តការគ្រប់គ្រងវិបត្តិដើម្បីទប់ទល់វិបត្តិកលិយុគ និងហានិភ័យផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ;
- បន្តពង្រឹងការអនុវត្តគោលនយោបាយគ្រប់គ្រងបំណុលសាធារណៈ ឱ្យស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន និងប្រកបដោយចីរភាព;
- បន្តពង្រឹងស្ថាប័នជាតិ និងប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាប្រសិទ្ធភាព, គណនេយ្យភាព និងតម្លាភាព និងធានាបានសមធម៌សង្គម និងឱកាសស្មើគ្នា;
- លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃសេវាសាធារណៈ ព្រមទាំងពង្រីកការទទួលបានការពេញចិត្តពីសេវាទាំងនេះ។

១៣- ដើម្បីឈានទៅសម្រេចគោលដៅខាងលើនេះ រាជរដ្ឋាភិបាលបានកំណត់គោលដៅសូចនាករហិរញ្ញវត្ថុសាធារណៈដូចខាងក្រោមនេះ÷

- ធានាកំណើនចំណូលចរន្ត ឱ្យសម្រេចបានក្នុងទំហំប្រមាណ ១៨,៦០% នៃ ផសស នៅឆ្នាំ ២០១៨ (ធៀបនឹងគោលដៅដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ត្រឹមតែ ១៧,៣៥% នៃ ផសស នៅក្នុងឆ្នាំ ២០១៨) ក្នុងនោះ គម្រោងចំណូលចរន្តសម្រាប់ថ្នាក់ជាតិ គឺ ១៧,៦៦% នៃ ផសស និងគម្រោងចំណូលចរន្តសម្រាប់ថ្នាក់ក្រោមជាតិ គឺ ០,៩៤% នៃ ផសស។ ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវបានគ្រោងសម្រេចឱ្យបាន ៨,៤១% នៃ ផសស, ចំណូលពីអគ្គនាយកដ្ឋានពន្ធដារត្រូវបានគ្រោងសម្រេចឱ្យបាន ៧,៦៩% នៃ ផសស និងចំណូលមិនមែនសារពើពន្ធត្រូវបានគ្រោងសម្រេចឱ្យបាន ២,៥០% នៃ ផសស។ ឈរលើមូលដ្ឋាននេះ ចំណូលក្នុងស្រុកសរុបសម្រាប់ឆ្នាំ ២០១៨ ត្រូវបានគ្រោងសម្រេចឱ្យបាន ១៨,៧៨% នៃ ផសស;
- ចំណាយសរុបនៅឆ្នាំ ២០១៨ នឹងត្រូវបានកំណត់ក្នុងរង្វង់ ២៤,៦៨% នៃ ផសស ក្នុងនោះចំណាយសម្រាប់រដ្ឋបាលថ្នាក់ជាតិត្រូវបានគ្រោង ២៣,៧៤% នៃ ផសស និង ចំណាយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានគ្រោង១,៦៨% នៃ ផសស (ឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិត្រូវបានគ្រោងចំនួន ០,៧៥% នៃ ផសស)។ ចំណាយចរន្តសរុបត្រូវបានគ្រោងក្នុងកម្រិត ១៥,៦៨% នៃ ផសស ដែលក្នុងនោះចំណាយបន្ទុកបុគ្គលិកត្រូវ

បានគ្រោងប្រមាណ ៥៣,៧% នៃចំណាយចរន្តសរុប ឬស្មើប្រមាណ ៨,៤២% នៃ ផសស ដោយផ្ដោតអាទិភាពលើការបង្កើនបៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ដើម្បីបង្កើនផលិតភាពការងារនិងពង្រឹងការផ្ដល់សេវាសាធារណៈ និងចំណាយមិនមែនបៀវត្សមួយចំនួន ពិសេសលើតម្រូវការចំណាយសម្រាប់ទ្រទ្រង់ការកែទម្រង់នានា និងការអនុវត្តគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល។ ជារួមចំណាយចរន្តថ្នាក់ជាតិ ត្រូវបានគ្រោងវិភាជទៅតាមវិស័យ ដូចខាងក្រោម÷

- **វិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងប្រមាណ ២,១១% នៃ ផសស និងមានកំណើន ៤,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៧,
- **វិស័យការពារជាតិ សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងប្រមាណ ៣,៨៩% នៃ ផសស និងមានកំណើន ១៥,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៧,
- **វិស័យសង្គមកិច្ច** ត្រូវបានគ្រោងប្រមាណ ៥,៤៥% នៃ ផសស និងមានកំណើន ១១,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៧,
- **វិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងប្រមាណ ១,៤៩% នៃ ផសស និងមានកំណើន ១២,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៧;

- ទន្ទឹមនឹងនេះដែរ សម្រាប់ឆ្នាំ ២០១៨ ចំណាយមូលធនត្រូវបានគ្រោងបង្កើនដល់ប្រមាណជា ៩,០% នៃ ផសស ក្នុងគោលដៅជួយទ្រទ្រង់ផលិតភាពសេដ្ឋកិច្ច,អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងជំរុញកំណើនសេដ្ឋកិច្ច;
- ឈរលើមូលដ្ឋានគម្រោងក្របខ័ណ្ឌចំណូល និងចំណាយខាងលើ អតិរេកថវិកាចរន្តសម្រាប់ឆ្នាំ ២០១៨ ត្រូវស្មើនឹង ២,៩២% នៃ ផសស ចំណែកឯឱនភាពថវិកាសរុបត្រូវបានកំណត់ត្រឹម ៥,៩០% នៃ ផសស ;
- នៅក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈខាងលើនេះ, ដើម្បីធានាតុល្យភាពថវិកា រាជរដ្ឋាភិបាលគ្រោងនឹងប្រើប្រាស់ប្រាក់បញ្ញើរបស់ខ្លួនចំនួនប្រមាណ ១,០% នៃ ផសស ត្រូវជា ៩៩៤ ៧៣៧ លានរៀល ក្នុងគោលបំណងបន្តគាំទ្រគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត សម្រាប់ការធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព, ការបន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើនភាពទាក់ទាញ និងភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា និងការដំឡើងបៀវត្សមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ តាមផែនការដែលបានគ្រោងទុក<u>(សូមពិនិត្យក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៦-២០១៨ មាននៅក្នុងឧបសម្ព័ន្ធ ២ ភ្ជាប់មកជាមួយ)</u>។

១៤- ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅខាងលើ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ការគ្រោងថវិកាឆ្នាំ ២០១៨ និងពេលខាងមុខ ត្រូវរៀបចំឡើងលើមូលដ្ឋានយុទ្ធសាស្ត្រ និងក្របខ័ណ្ឌនៃវិធានការ ដូចខាងក្រោម÷

ផ្នែកចំណូល

ក .ផ្នែកចំណូលពន្ធដារ

ដើម្បីពង្រឹងប្រភពចំណូលសំខាន់ៗ ក៏ដូចជាឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលអាចនឹងកើតមានក្នុងឆ្នាំ ២០១៨ វិធានការផ្នែកចំណូលពន្ធដារសម្រាប់បន្តអនុវត្តក្នុងឆ្នាំ ២០១៨ រួមមាន÷

- *បន្តពង្រឹងមុខងារប្រតិបត្តិការស្នូល ផ្ដោតលើការចុះបញ្ជីអ្នកជាប់ពន្ធ, ការផ្ដល់សេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម, ការស៊ើបអង្កេត, ការប្រមូលបំណុលពន្ធ និងបណ្ដឹងតវ៉ា តាមរយៈ ÷*
    - ការធ្វើបច្ចុប្បន្នកម្មបញ្ជីអ្នកជាប់ពន្ធឱ្យបានទៀងទាត់ និងទាន់ពេលវេលា ជាពិសេសបន្តការងារលុបសហគ្រាសដែលបាត់ខ្លួនចេញពីបញ្ជី,
    - ការពង្រឹងការចុះបញ្ជីពន្ធដារចំពោះសហគ្រាសដែលមិនទាន់បានចុះបញ្ជីពន្ធដារ ដែលរកឃើញដោយការធ្វើអង្កេតសហគ្រាស និងផ្ទៀងផ្ទាត់ព័ត៌មានជាមួយស្ថាប័នផ្សេងៗ,
    - ការផ្ដល់សេវាជូនអ្នកជាប់ពន្ធធំចំនួន ១៥០ សហគ្រាស តាមរយៈសិក្ខាសាលា និងការពិគ្រោះយោបល់ទាក់ទងនឹងប្រព័ន្ធពន្ធដារ និងរដ្ឋបាលសារពើពន្ធ,
    - ការរៀបចំការដាក់លិខិតប្រកាស និងការបង់ប្រាក់ Online (E-Filing and E-Payment),
    - ការបន្តជំរុញការអនុវត្តកាតព្វកិច្ចផ្ដល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់ និងបន្ថយបន្ទុកសវនកម្ម,
    - ការពង្រឹងការធ្វើសវនកម្មលើវិស័យដែលមានសក្ដានុពលមួយចំនួនដូចជា វិស័យនាំចេញ-នាំចូល វិស័យទេសចរណ៍ និងវិស័យសំណង់,
    - ការបន្តជ្រើសរើសសហគ្រាសដែលមានបុត្រសម្ព័ន្ធ (Group Companies) ជាអាទិភាពក្នុងការធ្វើសវនកម្ម ដោយសហការគ្នាជាក្រុម ដើម្បីរកឱ្យឃើញការគេចវេះពន្ធ និងការផ្ទេរថ្លៃ,
    - ការរៀបចំ និងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានស្ដីពីការផ្ទេរថ្លៃ (Transfer Pricing) ដើម្បីទប់ស្កាត់ការគេចវេះពន្ធ,
    - ការពង្រឹងការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការតឹងទារបំណុលពន្ធ ដែលមានចែងក្នុងបទប្បញ្ញត្តិស្ដីពីពន្ធដារ ដូចជាការរឹបអូស ឬការឃុំគ្រងទ្រព្យសម្បត្តិរបស់អ្នកជំពាក់បំណុលពន្ធ និងការប្ដឹងអ្នកជំពាក់បំណុលពន្ធទៅតុលាការ។
- *បន្តការពង្រឹងមុខងារគាំទ្រ តាមរយៈ÷*
    - ការរៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការអភិវឌ្ឍន៍ស្ថាប័ន,

- ការពង្រឹងប្រព័ន្ធសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មានឱ្យកាន់តែល្អប្រសើរ ដើម្បីឈានទៅការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការងារសវនកម្ម ប្រព័ន្ធផ្ទៀងផ្ទាត់អាករលើតម្លៃបន្ថែម (VAT Cross-Checking) និងប្រព័ន្ធគ្រប់គ្រងបំណុលពន្ធ,
- ការបង្កើតប្រព័ន្ធគ្រប់គ្រងអ្នកប្រើប្រាស់រួមតែមួយ (Core System-Single sign-on)។

ខ. ផ្នែកចំណូលគយ និងរដ្ឋាករ

ក្នុងទិសដៅបន្តពង្រឹងប្រភពចំណូលសំខាន់ ក៏ដូចជាឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលអាចនឹងកើតមានឡើង, វិធានការជាក់លាក់សម្រាប់ផ្នែកចំណូលគយ និងរដ្ឋាករ ដែលនឹងត្រូវអនុវត្តក្នុងឆ្នាំ ២០១៨ រួមមាន÷

- *ការបន្តពង្រឹងការត្រួតពិនិត្យ និងបញ្ចេញទំនិញផ្តោតលើ ការប្រកាសគយ, ការកំណត់ និងធ្វើចំណាត់ថ្នាក់ហានិភ័យ និងសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ តាមរយៈ ÷*
    - ការបន្តលើកកម្ពស់អនុលោមភាពនៃការគ្រប់គ្រងចុះបញ្ជីទំនិញនាពេលនាំចូលមកដល់ដែនគយទាំងផ្លូវគោកនិងផ្លូវទឹក ព្រមទាំងការជំរុញឱ្យមានការជម្រះបញ្ជីពេញលេញជាមួយប្រតិវេទន៍គយ ដោយត្រូវផ្តោតជាសំខាន់លើទំនិញដែលមានវេទយិតភាពចំណូលខ្ពស់ ទំនិញកំណត់ពិសេសស្ថិតក្រោមប្រព័ន្ធគ្រាពន្ធគយ និងទំនិញក្រោមរបបគយឆ្លងកាត់ប្រទេសជាប់ព្រំដែនរួចចូលកម្ពុជាតាមផ្លូវគោក,
    - ការចុះឃ្លាំមើលនិងវាយតម្លៃឱ្យបានទៀងទាត់របស់ថ្នាក់ដឹកនាំគយ និងសវនកររមានសមត្ថកិច្ចនូវប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋាន ជាពិសេសការអនុវត្តនីតិវិធីត្រួតពិនិត្យគយតាមអង្គភាពគយមូលដ្ឋានពាក់ព័ន្ធនឹងការប្រមូលចំណូលគយ,
    - ការលើកកម្ពស់ការយល់ដឹងនិងការទទួលខុសត្រូវរបស់មន្ត្រីគយ និងធុរជនលើនីតិវិធីគយ ជាពិសេសកាតព្វកិច្ចនានាពាក់ព័ន្ធនឹងការប្រកាស, ការបង់ពន្ធ, ការដឹកជញ្ជូនចែកចាយ និងការកាន់រក្សាទំនិញវេទយិត,
    - ការបន្តលើកកម្ពស់គុណភាពប្រព័ន្ធគ្រប់គ្រងហានិភ័យគយ និងប្រព័ន្ធព័ត៌មានសម្រាប់ជាមូលដ្ឋានក្នុងការបង្ក្រាបឬអនុវត្តយន្តការសវនកម្មតាមគ្រប់រូបភាព ព្រមទាំងការអនុវត្តនូវនីតិវិធីតាមផ្លូវតុលាការលើជនសង្ស័យឬជនល្មើសដែលមិនរាងចាល,
    - ការពង្រឹងប្រសិទ្ធភាពការងារត្រួតពិនិត្យរូបវ័ន្តលើទំនិញនៅយន្តការដើមទី ដោយអង្គភាពគយមូលដ្ឋានមានសមត្ថកិច្ចទាំងថ្នាក់ការិយាល័យ និងថ្នាក់សាខាគយឱ្យមានអនុលោមភាពពេញលេញជាមួយនីតិវិធីត្រួតពិនិត្យ ជាពិសេសការលើកកម្ពស់ការទទួលខុសត្រូវរបស់មន្ត្រីត្រួតពិនិត្យរូបវ័ន្តដោយភ្នែកទទេ និងតាមរយៈម៉ាស៊ីនស្កេន,

- ការដាក់ឱ្យអនុវត្តយន្តការផ្លាស់ប្តូរព័ត៌មានហានិភ័យផ្ទៃក្នុងគយ និងអន្តរស្ថាប័ន និងការលើកកម្ពស់កិច្ចសហការអន្តរស្ថាប័នទប់ស្កាត់និងបង្ក្រាបបទល្មើសគយ ជាពិសេសបទល្មើសគយជាក់ស្តែងពាក់ព័ន្ធនឹងការនាំចេញ-នាំចូលទំនិញតាមមាត់ច្រកទ្វេភាគី ឬច្រករបៀងខុសច្បាប់,
- ការបន្តលើកទឹកចិត្តឱ្យមានការចូលរួមរបស់ធុរជនល្អក្នុងការងារបង្ក្រាបបទល្មើសគយ ក្រោមក្របខណ្ឌនៃយន្តការភាពជាដៃគូគយ និងវិស័យឯកជន តាមរូបភាពនៃការចូលរួមផ្តល់ព័ត៌មានព្រមទាំងបទពិសោធន៍ល្អៗក្នុងតំបន់,
- ការបន្តពង្រឹងប្រសិទ្ធភាពយន្តការសវនកម្មគយតាមរយៈ ការលើកកម្ពស់សមត្ថភាពអង្គភាពសវនកម្ម ការពង្រីកភាពគ្របដណ្តប់នៃយន្តការនេះដល់គ្រប់វិស័យធុរកិច្ច និងការប្រើប្រាស់ទិន្នន័យហានិភ័យដែលប្រមូលបានពីប្រភពក្នុងនិងក្រៅប្រទេស;

- *<u>ការបន្តការពង្រឹងយន្តការគាំទ្រ តាមរយៈ÷</u>*
  - ការជំរុញអនុវត្តយន្តការសហការគយជាមួយស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ជាពិសេសជាមួយអគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីផ្ទៀងផ្ទាត់អនុលោមភាពពន្ធលើយានយន្តគ្រប់ប្រភេទនៅយន្តការកណ្តាលទី និងចុងទី ទាំងពេលនាំចូលសន្និធិ ពេលផ្គុំដំឡើង ពេលធ្វើផ្លាកលេខ និងពេលចរាចរចែកចាយតាមអាជីវកម្មដ្ឋាន ដោយផ្អែកលើប្រព័ន្ធទិន្នន័យ និងការកំណត់គម្យដ្ឋានច្បាស់លាស់ទាំងយានយន្តឯកជន យានយន្តរដ្ឋ ព្រមទាំងយានយន្តក្រោមរបបបណ្តោះអាសន្នផ្សេងៗ,
  - ការកសាង អនុវត្ត និងវាយតម្លៃការអនុវត្តផែនការសកម្មភាពឬគម្រោងលើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រងនិងអភិវឌ្ឍអង្គភាពគយ ជាពិសេសលើៈ (១)-រចនាសម្ព័ន្ធគ្រប់គ្រង (២)- សមត្ថភាពនិងសីលធម៌វិជ្ជាជីវៈមន្ត្រីគយ និង (៣)- ការបំពាក់មធ្យោបាយការងារទាំងមធ្យោបាយច្បាប់ និងមធ្យោបាយរូបវន្តផ្សេងទៀតឱ្យបានសមស្របដូចជា មធ្យោបាយប្រដេញនឹងប្រព័ន្ធទំនាក់ទំនងគមនាគមន៍ ព្រមទាំងការអនុវត្តប្រព័ន្ធលើកទឹកចិត្តមន្ត្រីគយមានស្នាដៃ និងដាក់ទណ្ឌកម្មមន្ត្រីគយអសកម្ម,
  - ការជំរុញពង្រឹងអនុលោមភាពអាជីវកម្មផលិតផលតេលសិលា និងថាមពលនាំចូល ដោយបន្តផ្សព្វផ្សាយនិងអនុវត្តឱ្យបានកាន់តែពេញលេញតាមការកំណត់របស់រាជរដ្ឋាភិបាលជាធរមាន ពាក់ព័ន្ធនឹងការធ្វើអាជីវកម្មនាំចូល សន្និធិ និងចរាចរចែកចាយផលិតផលតេលសិលា ជាពិសេសការជំរុញអនុវត្តវិធានការបិទការនាំចូលផលិតផលតេលសិលាតាមផ្លូវគោក,
  - ការបន្តពង្រីកភាពគ្របដណ្តប់និងមុខងារប្រព័ន្ធស្វ័យប្រវត្តិកម្មគយនានា ជាពិសេសការកសាងប្រព័ន្ធតភ្ជាប់ដោយមធ្យោបាយអេឡិចត្រូនិករវាងប្រព័ន្ធតម្លៃគិតពន្ធគយ ប្រព័ន្ធគ្រប់គ្រងហានិភ័យ ប្រព័ន្ធស្ថិតិគយ ជាមួយប្រព័ន្ធស្វ័យប្រវត្តិកម្មគយផ្សេងទៀត ក៏ដូចជាជាមួយអគ្គនាយកដ្ឋានពន្ធដារ,

- ការបន្តវាយតម្លៃជាប្រចាំនូវផលប៉ះពាល់លើចំណូលគយពីបញ្ហាប្រឈមនានា និងការធ្វើវិចារណកម្ម និងពិពិធកម្មគោលនយោបាយគយនានា សំដៅប៉ះប៉ូវចំណូលគយដែលបាត់បង់ពីបញ្ហាប្រឈមនីមួយៗឱ្យបានសមស្របនិងទាន់ពេលវេលាជាពិសេស(១)-ការបន្តពិនិត្យលទ្ធភាពដំឡើងអត្រាអាករពិសេស (២)-ការពង្រឹងសមត្ថភាពបង្ក្រាបបទល្មើស និងការកាត់បន្ថយការលើកទឹកចិត្តពន្ធអាករហួសពីការអនុវត្តល្អក្នុងតំបន់ និង(៣)-ការចាត់វិធានការមុតស្រួចនានាបន្ថែមទៀត ដើម្បីរក្សាចីរភាពកំណើនចំណូលគយតាមគោលនយោបាយរាជរដ្ឋាភិបាល។

<u>គ.ផ្នែកចំណូលមិនមែនសារពើពន្ធ</u>

ដើម្បីពង្រឹងប្រភពចំណូលសំខាន់ ក៏ដូចជាឆ្លើយតបទៅនឹងបញ្ហាប្រឈមសំខាន់ៗដែលអាចនឹងកើតមានឡើងក្នុងឆ្នាំ ២០១៨ វិធានការសម្រាប់អនុវត្តក្នុងឆ្នាំ ២០១៨ (មិនមែនជាវិធានការជាក់លាក់ក្នុងឆ្នាំទេ) ប៉ុន្តែជាវិធានការប្រចាំគ្រាសំខាន់ៗ ដែលត្រូវបន្តអនុវត្ត រួមមាន÷

- បន្តសម្របសម្រួលដំណើរការរបស់គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ;
- បន្តសម្របសម្រួលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលតាមក្រសួង-ស្ថាប័នដែលទទួលខុសត្រូវក្នុងការតាមដាន, កត់ត្រា, កៀរគរចំណូល និងចាត់វិធានការតឹងទារបំណុល;
- បន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង ការកត់ត្រា និងការផ្តល់របាយការណ៍ចំណូលមិនមែនសារពើពន្ធ ឱ្យកាន់តែមានតម្លាភាព និងទាន់ពេលវេលា ដោយពង្រឹងការគ្រប់គ្រងស្ថាប័ន, ការទទួលខុសត្រូវច្បាស់លាស់, ការដាក់ទណ្ឌកម្ម, សវនកម្ម និងអធិការកិច្ច តាមរយៈអនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធដែលនឹងត្រូវបញ្ចប់ក្នុងពេលឆាប់ៗ;
- បន្តរកមុខចំណូលថ្មីៗ និងពង្រឹងការប្រមូលមុខចំណូលដែលមានស្រាប់ ដែលមិនប៉ះពាល់ដល់ជីវភាពរបស់ប្រជាជនទូទៅ ក្នុងនោះរួមមានការបន្តស្វែងយល់ពីបទពិសោធន៍ពីប្រទេសដទៃទៀត;
- បន្តពង្រឹងយន្តការគណៈកម្មការអន្តរក្រសួង ដើម្បីទប់ស្កាត់មិនឱ្យមានបំណុលថ្មី និងការតឹងទារបំណុល;
- បន្តជំរុញការរៀបចំប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធតាមប្រព័ន្ធព័ត៌មានវិទ្យា ដែលកំពុងរៀបចំដោយក្រុមការងាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឈានទៅការបញ្ចប់ឱ្យបានឆាប់នូវការរៀបចំប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ;
- បន្តជំរុញការប្រើប្រាស់ប្រព័ន្ធធនាគារ ក្នុងការបង់ចំណូលទៅគណនីទោលរបស់រតនាគារជាតិឱ្យគ្រប់ចំនួន និងទាន់ពេលវេលា;
- ស្នើអាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធរបស់ក្រសួងស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ;
- ជំរុញអនុវត្ត និងកែលម្អស្តង់ដារសេវាសម្រាប់បង់ចំណូល ឱ្យមានភាពងាយស្រួល និងតម្លាភាព;

- បន្តពង្រឹងការប្រមូលកម្រៃពីសេវាដឹកអ្នកដំណើរតាមអាកាស ដែលបច្ចុប្បន្ន អគ្គនាយកដ្ឋានទ្រព្យរដ្ឋ និងចំណូលមិនមែនសារពើពន្ធ កំពុងសហការជាមួយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដើម្បីបង្កើតកម្រៃ ៤ ដុល្លារអាមេរិក សម្រាប់អ្នកដំណើរក្នុងប្រទេស និង ៦ ដុល្លារអាមេរិក សម្រាប់អ្នកធ្វើដំណើរក្រៅប្រទេស;
- បន្តពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ច ដោយផ្អែកលើគោលកាណ៍កំណត់របស់រាជរដ្ឋាភិបាល;
- បន្តរៀបចំនិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តិ ដើម្បីកៀរគរចំណូលពីវិស័យកាស៊ីណូ និងឆ្នោតឡូតូ;
- បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងអាជីវកម្ម Online;
- ជំរុញការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរមណីយដ្ឋានសមាហរណល្បែងពាណិជ្ជកម្មឱ្យចេញនៅឆ្នាំ ២០១៨;
- បន្តកិច្ចសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីបង្ក្រាបអាជីវកម្មល្បែងខុសច្បាប់។

ផ្នែកចំណាយ

ដោយឈរលើមូលដ្ឋានការអនុវត្តចំណាយសាធារណៈកន្លងមក និងដើម្បីសម្រេចបានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃគោលនយោបាយវិត្តារកម្មចំណាយសាធារណៈ, រាជរដ្ឋាភិបាលចាំបាច់ត្រូវអនុវត្តវិធានការ និងគោលការណ៍ជាក់លាក់មួយចំនួនក្នុងឆ្នាំ ២០១៨ ដែលរួមមាន÷

- បន្តការគិតគូរពីការរៀបចំថវិកាឱ្យកាន់តែមានលក្ខណៈផ្សារភ្ជាប់ ទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល តាមរយៈការបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកាឈរលើមូលដ្ឋានចាំបាច់, ជាក់ស្តែង និងចំទិសដៅ ពិសេសការពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ស្របជាមួយនឹងការពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តថវិកា;
- ពង្រីកការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាឱ្យបានគ្រប់ក្រសួង-ស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ;
- បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធឱ្យទទួលបានលើស ១ លានរៀល នៅឆ្នាំ ២០១៨ ក្នុងគោលដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព, សមធម៌, សង្គតិភាព ចីរភាពថវិកា និងស្ថិរភាពសេដ្ឋកិច្ច;
- បន្តរក្សាអាទិភាព និង វិចារណកម្មនៃគោលនយោបាយចំណាយនៅក្នុងវិស័យអប់រំ, បណ្តុះបណ្តាលវិជ្ជាជីវៈ, ប្រព័ន្ធដឹកជញ្ជូន និងឡជីស្ទីក, កសិកម្ម និងប្រព័ន្ធគាំពារសង្គម;
- បន្តធ្វើវិត្តារកម្មគោលនយោបាយចំណាយ (រួមជាមួយការបន្តរឹតត្បិតចំណាយមិនចាំបាច់) ក្នុងស្មារតីគាំទ្រដល់ "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម" និងគាំទ្រដល់ការទ្រទ្រង់ចីរភាពកំណើនសេដ្ឋកិច្ច

សម្រាប់រយៈពេលមធ្យម និងវែង តាមរយៈការបង្កើនការចំណាយវិនិយោគសាធារណៈលើការពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជា ផ្លូវថ្នល់, ផ្លូវដែក, កំពង់ផែ, ប្រព័ន្ធធារាសាស្ត្រស្រោចស្រព និងអគ្គិសនី។ល។ ដើម្បីផ្តល់ភាពងាយស្រួលដល់វិនិយោគិន, ពាណិជ្ជករ និងប្រជាជន;

- បង្កើនការយកចិត្តទុកដាក់លើចំណាយថែទាំឱ្យមានប្រសិទ្ធភាព ក្នុងទិសដៅកែលម្អ និងពង្រឹងការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត;
- បន្តផ្តោតការយកចិត្តទុកដាក់ និងបង្កើនការវិនិយោគសាធារណៈឱ្យចំវិស័យដែលផ្តល់ផលិតភាពខ្ពស់ ក្នុងគោលដៅទ្រទ្រង់កំណើនប្រកបដោយចីរភាព ដូចជា វិស័យកសិកម្ម វិស័យចំណីអាហារ និងវិស័យគាំទ្រដើម្បីជំរុញផលិតភាព, តម្លៃបន្ថែម និងជំរុញការកែច្នៃកសិផលសម្រាប់ការនាំចេញ, ការចិញ្ចឹមសត្វ ការដាំបន្លែ និងវារីវប្បកម្ម តាមរយៈវិចារណកម្មគោលនយោបាយចំណាយក្នុងទិសដៅទទួលបានប្រសិទ្ធភាពខ្ពស់;
- បន្តជំរុញអនុវត្ត**កម្មវិធីសាច់ប្រាក់ពលកម្ម (Cash For Work)** ដែលជាកម្មវិធីជួយស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ និងជាកម្មវិធីអន្តរាគមន៍ដោយត្រង់របស់រាជរដ្ឋាភិបាលក្នុងការបង្កើតការងារនៅទីជនបទដែលគាំទ្រដល់វិស័យជំនាញទប់ស្កាត់ការធ្វើចំណាកស្រុក, បង្កើនផលិតភាពនិងលើកកម្ពស់ជីវភាពប្រជាជននៅទីជនបទ;
- លើកកម្ពស់ប្រសិទ្ធភាពនៃប្រតិបត្តិការចំណាយ តាមរយៈការបង្កើនតម្លៃនៃលុយ ដោយផ្តោតការយកចិត្តទុកដាក់លើភាពសមស្របនៃថ្លៃ, បរិមាណ, គុណភាព និងភាពទាន់ពេលនៃថវិកាដែលបានចំណាយ ទាំងចំណាយចរន្ត (ចំណាយបុគ្គលិក និងមិនមែនបុគ្គលិក) និងចំណាយមូលធន;
- បន្តពង្រឹងការគ្រប់គ្រងចំណាយសាធារណៈ ជាពិសេសបន្តពង្រឹង និងជំរុញការកែលម្អការអនុវត្តថវិកា តាមរយៈការបន្តកាត់បន្ថយនីតិវិធីចំណាយ, ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់, ការបន្តពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស, ការបន្តត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងឆមាស, ការបន្តពង្រឹងការត្រួតពិនិត្យផ្ទៃក្នុងដើម្បីបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកាដែលសម្រេចបាន និងបន្តបង្កើនប្រសិទ្ធភាពគណនេយ្យភាពហិរញ្ញវត្ថុ និងជំហានបន្ទាប់ផ្សេងៗទៀត;
- គិតគូរឱ្យមានកញ្ចប់ថវិការត្រៀមបម្រុងសម្រាប់ដោះស្រាយតម្រូវការបន្ទាន់ ក្នុងករណីមានតម្រូវការចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាល, វិបត្តិផ្សេងៗ និងប្រធានស័ក្តិ;
- លើកកម្ពស់ប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន ទាំងពីប្រភពថវិការដ្ឋ, ប្រភពហិរញ្ញប្បទានក្រៅប្រទេស និងទាំងពីប្រភពថវិការបស់ដៃគូឯកជនអនុវត្តតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន ដោយត្រូវបង្កើតឱ្យមាននូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមមួយ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ, ប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព និងគណនេយ្យភាព តាមរយៈ÷

- ការរៀបចំក្របខ័ណ្ឌនិងគោលការណ៍រួមសម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈ ពីគ្រប់ប្រភពហិរញ្ញប្បទាន ដែលគ្រោងនឹងដាក់ឱ្យអនុវត្តដោយអនុក្រឹត្យនៅមុនដំណាច់ឆ្នាំ២០១៧,
- ការរៀបចំគោលការណ៍ និងនីតិវិធីលម្អិតសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានពីប្រភពថវិកាជាតិ ដែលគ្រោងដាក់ឱ្យអនុវត្តដោយអនុក្រឹត្យនៅក្នុងឆ្នាំ២០១៨,
- ការពិនិត្យ និងធ្វើបច្ចុប្បន្នកម្មលើនីតិវិធីរួមសម្រាប់គ្រប់គ្រងនិងអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តដោយអនុក្រឹត្យនៅក្នុងឆ្នាំ២០១៨, និង
- ការរៀបចំក្របខ័ណ្ឌគតិយុត្ត យន្តការស្ថាប័ន និងនីតិវិធីប្រតិបត្តិការរួម សម្រាប់គ្រប់គ្រងការរៀបចំ និង អនុវត្តគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន ដែល-គ្រោងនឹងដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៨;

- បន្តអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុល និងបន្តពង្រឹងបន្ថែម សមត្ថភាពស្ថាប័ន ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ក្នុងគោលដៅបន្តរក្សាចីរភាពនៃការគ្រប់គ្រងបំណុល។

III- សន្និដ្ឋាន

១៥. ជារួម ស្ថានភាពសេដ្ឋកិច្ចកម្ពុជានឹងបន្តមានលក្ខណៈល្អប្រសើរ ប៉ុន្តែទាមទារឱ្យមានការពន្លឿនការកែ-ទម្រង់រចនាសម្ព័ន្ធ និងការធ្វើពិពិធកម្មសេដ្ឋកិច្ចទៅរកអនុវិស័យថ្មីៗដែលមានតម្លៃបន្ថែមខ្ពស់ រួមមានៈ ខ្សែចង្វាក់ផលិតកម្មនៅក្នុងឧស្សាហកម្មកាត់ដេរ, កែច្នៃម្ហូបអាហារ, ការដំឡើងគ្រឿងម៉ាស៊ីន, គ្រឿងអេឡិចត្រូនិច និងឧស្សាហ-កម្មថ្មីទៀត ដែលជំរុញសកម្មភាពសេដ្ឋកិច្ច ដើម្បីសម្រេចឱ្យបានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំក្នុងរង្វង់ ៧% ជាពិសេសតាមរយៈការដាក់ចេញ និងអនុវត្តនូវវិធានការគោលនយោបាយដែលមានលក្ខណៈឆ្លើយតប ទាំងក្នុងផ្នែកម៉ាក្រូសេដ្ឋ-កិច្ច និងផ្នែកហិរញ្ញវត្ថុសាធារណៈ និងត្រូវបន្តតាមដានយ៉ាងប្រុងប្រយ័ត្ន និងដាក់ចេញនូវវិធានការគន្លឹះដើម្បីបញ្ចៀសហានិភ័យជាយថាហេតុ ក្នុងបរិការណ៍ដែលទស្សនៈវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោកកំពុងស្ថិតនៅក្នុងភាពផុយស្រួយ និងមិនប្រាកដប្រជាខ្ពស់។ ក្នុងបរិការណ៍នេះ, ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០១៨ បានដាក់ចេញនូវគោលដៅក្នុងការសម្រេចឱ្យបានកំណើនសេដ្ឋកិច្ចប្រមាណ ៧% ខណៈអត្រាអតិផរណាមធ្យមប្រចាំឆ្នាំត្រូវរក្សាឱ្យស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងប្រមាណ ៣,៥%។ ជាមួយគ្នានេះដែរ ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ ២០១៨ ក៏ត្រូវបានគ្រោងសម្រេចអតិរេកថវិកាចរន្តក្នុងរង្វង់២,៩២% នៃ ផសស ហើយឱនភាព ថវិកាសរុបនឹងត្រូវបានគ្រោងក្នុងកម្រិត ៥,៩០% នៃ ផសស ក្នុងទិសដៅបង្កើនលំហថវិកាសម្រាប់ឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍ ក៏ដូចជាសម្រាប់ត្រៀមជាស្រេចក្នុងការឆ្លើយតបនឹងតម្រូវការជាយថាហេតុផ្សេងទៀត ដែលអាចកើតមានឡើងនៅក្នុងឆ្នាំ។

១៦. ការកំណត់គោលដៅក្នុងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈខាងលើ គឺជាកត្តាគន្លឹះក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនខ្ពស់ប្រកបដោយបរិយាប័ន្ន, ការបែងចែកផ្លែផ្កាកំណើនកាន់តែប្រសើរ និងការបង្កើនគុណភាពជីវិត ជាពិសេសធានាបាននូវការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច ដើម្បីរក្សាកំណើនប្រកបដោយចីរភាពក្នុងរយៈពេលមធ្យម និងវែង។ ទោះជាយ៉ាងណាក៏ដោយ, ដើម្បីសម្រេចគោលដៅនេះ វិធានការដែលបានដាក់ចេញខាងលើ ត្រូវតែមានការចូលរួមអនុវត្តជាបន្ទាន់ និងប្រកបដោយប្រសិទ្ធភាពពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ដើម្បីឱ្យកម្ពុជាឈានឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យ និងបំណងប្រាថ្នារយៈពេលវែង ក្នុងការប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ ២០៣០ និងប្រទេសចំណូលខ្ពស់ត្រឹមឆ្នាំ ២០៥០។ ទន្ទឹមនឹងនេះ, ក្របខ័ណ្ឌគោលនយោបាយខាងលើ ក៏បានឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងក្នុងការកៀរគរចំណូល, ទាំងផ្នែកសារពើពន្ធ និងមិនមែនសារពើពន្ធ, ស្របពេលនឹងការបន្តធ្វើវិចារណកម្មចំណាយឱ្យកាន់តែចំទិសដៅ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ជាងមុន តាមរយៈកម្មវិធី និងវិធានការមុតស្រួចដែលបានដាក់ចេញ។ ជារួម ក្របខ័ណ្ឌគោលនយោបាយនេះ ក៏ជាទិសដៅរបស់រាជរដ្ឋាភិបាលក្នុងការសម្រេចឱ្យបានសមិទ្ធផលជាផ្លែផ្កា និងការសន្យាដែលនៅសេសសល់ទាំងអស់របស់រាជរដ្ឋាភិបាលនីតិកាលទី ៥ ចំពោះប្រជាជនកម្ពុជា ដើម្បីធានាបានវឌ្ឍនភាព, ឯករាជ្យភាព និងភាពជាម្ចាស់របស់កម្ពុជាក្នុងការគ្រប់គ្រងជោគវាសនារបស់ខ្លួនសម្រាប់ការអភិវឌ្ឍរយៈពេលវែងបន្តទៅមុខទៀត។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ មីនា ឆ្នាំ ២០១៧

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ